**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

# ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២
# របស់អាជ្ញាធរទន្លេសាប

រៀបចំដោយ ៖ អាជ្ញាធរទន្លេសាប
សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
ខែមករា ឆ្នាំ ២០២២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

លេខ :...០០៩.........អទស

ថ្ងៃ អង្គារ ១៥ រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ គ.ស. ២០២២

**ជម្រាបមក**

**ឯកឧត្តមអនុប្រធាន ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង**
**លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋានក្រោមឱវាទ**
**អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប**

**កម្មវត្ថុ ៖** ការដាក់ឲ្យអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប ។

**ជូនភ្ជាប់៖** ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប ។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋាន ជ្រាបថា ៖ ក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយចីរភាព ។

អាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២ ដើម្បីជម្រុញប្រសិទ្ធភាពការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបឆ្នាំ ២០២១-២០២៥ ឲ្យទទួលបានជោគជ័យ និងបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីសក្តានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ស្របតាមអាណត្តិការងារសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប អនុវត្តន៍ឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

អគារលេខ: ៣៦៤,មហាវិថី ព្រះមុនីវង្ស,សង្កាត់ ផ្សារដើមថ្កូវ,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
# 364 Monivong Blvd., Phsar Deumthkov, Khan Chamkarmorn, Phnom Penh, Cambodia. Phone/Fax: (855) 23 727 454, Website: www. tonlesap.gov.kh

# មាតិកា

**បុព្វកថា** ...... 1
**ផ្នែកទី១ សេចក្តីផ្តើម** ...... 3
១.១- សាវតារ ...... 3
១.២- អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ...... 5
**ផ្នែកទី២ វឌ្ឍនភាពការអនុវត្តផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២១** ...... 6
២.១- សេចក្តីផ្តើម ...... 6
២.២- វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ ២០២១ ...... 6
២.៣- មេរៀន និងបទពិសោធន៍ ...... 9
**ផ្នែកទី៣ អំពីផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥** ...... 10
ដ្យាក្រាមទី២ គំនូសបំព្រួញរចនាសម្ព័ន្ធនៃចក្ខុវិស័យ បេសកកម្ម និងសសរស្តម្ភ ...... 10
៣.១- ចក្ខុវិស័យ និងបេសកកម្ម ...... 11
៣.២- គោលដៅយុទ្ធសាស្ត្រ និងគោលបំណង ...... 11
៣.៣- បាវចនា និងរចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប ...... 11
ដ្យាក្រាមទី៣ រចនាសម្ព័ន្ធអាជ្ញាធរទន្លេសាប ...... 12
៣.៤- ទិសដៅយុទ្ធសាស្ត្រ ...... 13
៣.៥- សកម្មភាពយុទ្ធសាស្ត្រ ...... 13
**ផ្នែកទី៤ ផែនការសកម្មភាពរបស់អាជ្ញាធរទន្លេសាប ២០២២** ...... 18
៤.១- សេចក្តីផ្តើម ...... 18
៤.២- សកម្មភាពការងារឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប ...... 18
៤.៣- តារាងទី ១៖ ម៉ាទ្រិកផែនការសកម្មភាពឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប ...... 25
**ផ្នែកទី៥ យន្តការអនុវត្ត និងប្រភពថវិកា ធនធានហិរញ្ញវត្ថុ** ...... 60
៥.១- យន្តការសម្រាប់អនុវត្ត ...... 60
៥.២- ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ ...... 60
តារាងទី២៖ ការប៉ាន់ប្រមាណថវិកាសម្រាប់សកម្មភាពឆ្នាំ ២០២២ ...... 61
**ផ្នែកទី៦ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្តីសន្និដ្ឋាន** ...... 62
៦.១- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ...... 62
៦.២- សេចក្តីសន្និដ្ឋាន ...... 63
**ឧបសម្ព័ន្ធ** ...... 64
ឧបសម្ព័ន្ធទី១ រចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ របស់អាជ្ញាធរទន្លេសាប ...... 64
ឧបសម្ព័ន្ធទី២ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ...... 65

ឧបសម្ព័ន្ធទី៣ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពីការកែសម្រួល មាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/ ៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប.............................. 72
ឧបសម្ព័ន្ធទី៤ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ..................................................... 77
ឧបសម្ព័ន្ធទី៥ ប្រកាសលេខ ០២៥ អ.ទ.ស ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ការិយាល័យ ចំណុះបណ្តានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ....... 82
ឧបសម្ព័ន្ធទី៦ អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹក ចំនួន ៦៤៧.៤០៦ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប................... 89

# បុព្វកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃប្រទេសកម្ពុជាដែលមានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប គឺជាប្រព័ន្ធផ្លូវទឹកទំនាក់ទំនងយ៉ាងសំខាន់បំផុត ដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ បឹងទន្លេសាប ស្រូបយកទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយកម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិ ចាក់បំពេញវាលទំនាបលិចទឹកនៃតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលជាជម្រក និងបង្កបានជាចំណី សម្រាប់ជីវចម្រុះយ៉ាងសម្បូរបែបមានពពួកមច្ឆជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ក្រៅពីតួនាទីជាបឹង ទទួលយកទឹកនិងជួយកាត់បន្ថយគ្រោះទឹកជំនន់ពីទន្លេមេគង្គ វាក៏ជាប្រភពសន្តិសុខស្បៀង ជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងជួយទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានប្រទេសជាតិទាំងមូល ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ និងកំណើនប្រជាពលរដ្ឋ បានធ្វើឲ្យមានហានិភ័យនៃបឹងទន្លេសាបបាននឹងកំពុងទទួលរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់សុខមាលភាពបឹង បរិស្ថាន ជីវចម្រុះ និងធនធានធម្មជាតិ ដូចជា ៖ ការប្រើប្រាស់បច្ចេកវិទ្យាទំនើប បច្ចេកវិទ្យាកែច្នៃ ការកាប់បំផ្លាញ រុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានជលផល បម្រែបម្រួលអាកាសធាតុ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់ទំនប់វារីអគ្គិសនីនៅផ្នែកខាងលើជាដើម ។

ដោយមើលឃើញពីសារៈសំខាន់នៃបឹងទន្លេសាប និងដើម្បីចូលរួមចំណែកក្នុងកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានដ៏កម្រនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព ក៏ដូចជាការចូលរួមពង្រឹងប្រសិទ្ធភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរទន្លេសាបបានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២២ ដែលជាផែនការសកម្មភាពនៃឆ្នាំទី៩(ជារួម) និងជាផែនការសកម្មភាពឆ្នាំទី២ នៃផែនការយុទ្ធសាស្ត្រលើកទី២ (២០២១-២០២៥) ។

ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២ គឺជាសកម្មភាពការងារលម្អិត ក្នុងការប្រតិបត្តិការងារប្រចាំឆ្នាំរបស់ អាជ្ញាធរទន្លេសាប រួមជាមួយការចូលរួមសហការពីបណ្តាក្រសួង ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២១-២០២៥ ឲ្យទទួលបានជោគជ័យ ។ ជាមួយខ្លឹមសារផែនការសកម្មភាពការងារនេះ ក៏ត្រូវបានរៀបចំបន្ស៊ីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២១-២០២៥ ។ ជាពិសេស ស្របតាមតួនាទីភារកិច្ចការងារ ដែលបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន

នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

ផែនការសកម្មភាពការងារនេះ ចែកជា ៦ ផ្នែកសំខាន់ៗគឺ ៖

- ផ្នែកទី១ សេចក្តីផ្តើម ដែលរៀបរាប់អំពី សាវតារ រចនាសម្ព័ន្ធ តួនាទីភារកិច្ច និងអាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ។
- ផ្នែកទី២ រំលឹកអំពីវឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២១
- ផ្នែកទី៣ អំពីផែនការយុទ្ធសាស្រ្ត(២០២១-២០២៥)
- ផ្នែកទី៤ ផែនការសកម្មភាពឆ្នាំ២០២២ របស់អាជ្ញាធរទន្លេសាប
- ផ្នែកទី៥ យន្តការអនុវត្ត និងប្រភពថវិកា ធនធានហិរញ្ញវត្ថុ
- ផ្នែកទី៦ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្តីសន្និដ្ឋាន

ជាក់ស្តែង ផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២២ នេះ នឹងប្រើប្រាស់ធ្វើជាឧបករណ៍ជួយតម្រង់ទិសការងារអគ្គលេខាធិការដ្ឋាន នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប សម្រាប់យកទៅអនុវត្តឲ្យមានប្រសិទ្ធភាព ហើយក៏ជាទស្សនទានដ៏សំខាន់មួយ សម្រាប់ផ្តល់ជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគិតគូរពិចារណាធ្វើការវិភាជន៍ថវិកាប្រចាំឆ្នាំ និងដៃគូអភិវឌ្ឍនានា ដែលមានគោលបំណងចូលរួមសហការ និងគាំទ្រទាំងផ្នែកថវិកា បច្ចេកទេស និងធនធានមនុស្ស ដល់ដំណើរការការងាររបស់អាជ្ញាធរទន្លេសាប ។

# ផ្នែកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

ដើម្បីធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព និងសម្រាប់រក្សាទុកជាកេរ្តិ៍មរតកដ៏ប្រពៃរបស់មនុស្សជាតិយូរអង្វែង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបង្កើតស្ថាប័នថ្មីមួយស្ថិតក្រោមការគ្រប់គ្រងនៃ**ទីស្តីការគណៈរដ្ឋមន្ត្រី** និងជាសេនាធិការផ្ទាល់បន្ថែមជួយដល់រាជរដ្ឋាភិបាលគឺ **អាជ្ញាធរអាងទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧។ យោងលើការពិនិត្យជាក់ស្តែងរាជរដ្ឋាភិបាល បានធ្វើកំណែទម្រង់ឡើងវិញលើរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងតួនាទីភារកិច្ច ក៏ដូចជាដែនសមត្ថកិច្ច វិសាលភាពនៃការគ្រប់គ្រងរបស់អាជ្ញាធរអាងទន្លេសាប មកជា **អាជ្ញាធរទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា ១០ និងមាត្រា១២ ស្តីពីការបង្កើត អាជ្ញាធរទន្លេសាប។

ជាមួយនឹងបេសកកម្មការងារ និងតួនាទីភារកិច្ចស្នូលក្នុងការទទួលខុសត្រូវ ចំពោះមុខរាជរដ្ឋាភិបាល **អាជ្ញាធរទន្លេសាប** បានរៀបចំបង្កើតឡើងនូវ **អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប** ដូចមានកំណត់ក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៦៦ អនក្របក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ចែងទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

យោងតាមមាត្រា ២ ជំពូកទី ២ នៃអនុក្រឹត្យ ដែលចែងពីតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប មានដូចខាងក្រោម ៖

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួលរាល់សកម្មភាពការងារប្រចាំថ្ងៃរបស់អាជ្ញាធរទន្លេសាប
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនៈវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប

- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្រ្ត កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរទន្លេសាប
- អនុវត្តភារកិច្ចផ្សេងៗ ដែលប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន ។

## ២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង

យោងតាមអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ **អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប** ក្នុងមាត្រា ៣ ជំពូក ៣ ដែលចែងពីរចនាសម្ព័ន្ធ និងការគ្រប់គ្រង គឺមាននាយកដ្ឋានចំនួន ០៤ អមដោយការិយាល័យចំនួន ១៤ និងបានកំណត់ពីតួនាទី ភារកិច្ចទទួលខុសត្រូវតាមនាយកដ្ឋាន និងការិយាល័យ នីមួយៗដូចមានចែងក្នុងប្រកាសលេខ ០២៥ អទស ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទ រួមមាន ៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ការិយាល័យចំនួន ០៤
- នាយកដ្ឋានធនធានធម្មជាតិ ការិយាល័យចំនួន ០៤
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ការិយាល័យចំនួន ០៣
- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ការិយាល័យចំនួន ០៣

ជាក់ស្តែង ការរៀបចំកសាងផែនការសកម្មភាពប្រចាំឆ្នាំ ២០២២ របស់ **អាជ្ញាធរទន្លេសាប** ក្នុងបំណងឆ្លុះបញ្ចាំងឲ្យឃើញពីទិសដៅ និងសកម្មភាពការងារអាទិភាពប្រចាំឆ្នាំ ដើម្បីជំរុញដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្រ្តរយៈពេល ៥ ឆ្នាំ (២០២១-២០២៥) របស់អាជ្ញាធរទន្លេសាប ឲ្យទទួលបានជោគជ័យ តាមគោលដៅជាយុទ្ធសាស្រ្តទាំង ៤ និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប ក្នុងបេសកកម្មស្នូល **សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប** ។

## ១.២. អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ត្រូវដើរតួនាទីយ៉ាងសំខាន់ ជាពិសេស អាជ្ញាធរទន្លេសាប ត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាបំផុត ចំពោះការអនុវត្តផែនការសកម្មភាពការងារឆ្នាំ ២០២២ ស្របទៅតាមចំណុចអាទិភាពចម្បងដូចខាងក្រោម៖

- កៀរគរបង្កើនធនធានហិរញ្ញវត្ថុដើម្បីបង្កលទ្ធភាពដល់ការចុះសិក្សាស្រាវជ្រាវជាមូលដ្ឋានឲ្យបានពេញលេញស្របតាមមុខងាររបស់ស្ថាប័ន/អង្គភាពប្រចាំថ្ងៃ
- បន្តពង្រឹងពង្រីកលើការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្សនិងអភិវឌ្ឍលើការចែករំលែក និងផ្សព្វផ្សាយ អំពីដំណើរការអនុវត្តសកម្មភាពបច្ចេកទេសដែលជាមូលដ្ឋានគ្រឹះរួមមាន៖
    - ពង្រឹងពង្រីកការពិគ្រោះយោបល់ ការចែករំលែក និងផ្សព្វផ្សាយពីបច្ចេកទេសនៃការសិក្សាស្រាវជ្រាវ លទ្ធផលរបកគំហើញពាក់ព័ន្ធនឹងសក្ដានុពល និងផលប៉ះពាល់ផ្សេងៗនៃតំបន់បឹងទន្លេសាប ជំរុញសកម្មភាពអាជ្ញាធរទន្លេសាប ឲ្យដើរតួនាទីជាអង្គភាពថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការចែករំលែក និងផ្សព្វផ្សាយព័ត៌មានទិន្នន័យដល់ភាគីពាក់ព័ន្ធ
    - រៀបចំ និងផ្សព្វផ្សាយពីរបាយការណ៍ ស្ដីពីស្ថានភាពតំបន់បឹងទន្លេសាប
    - រៀបចំ និងផ្សព្វផ្សាយពីគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព
    - រៀបចំ និងផ្សព្វផ្សាយពីផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព
    - ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិឲ្យកាន់តែស៊ីជម្រៅ
- ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព័ត៌មានវិទ្យាសាស្ត្រតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ជំរុញក្រុមការងារ/ជំនាញផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងការគ្រប់គ្រងគម្រោងរួមជាមួយមន្ត្រីរាជការបម្រើការងារនៅអាជ្ញាធរទន្លេសាបដែលមានជំនាញពាក់ព័ន្ធផ្សេងៗ ដើម្បីជួយដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រឲ្យសម្រេចបានជោគជ័យ
- លើកកម្ពស់ភាពជាដៃគូ រួមទាំងដៃគូបច្ចេកទេស ធនធានមនុស្ស និងហិរញ្ញវត្ថុ។

# ផ្នែកទី ២

## វឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២១

### ២.១. សេចក្តីផ្តើម

ផែនការសកម្មភាពប្រចាំឆ្នាំ ២០២១ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដែលបានរៀបចំឡើង ក្នុងការចូលរួមចំណែកលើកកម្ពស់ការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលឈានទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍសហវត្សរ៍កម្ពុជា ។ ផែនការសកម្មភាពនេះ បានកំណត់ពីសកម្មភាពការងារអាទិភាពរបស់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីអនុវត្តសម្រេចនូវគោលបំណង លទ្ធផល (Outcome) និងធាតុចេញ (Output) ដោយប្រើប្រាស់នូវកញ្ចប់ថវិកាជាតិប្រចាំឆ្នាំ ២០២១ ។

### ២.២ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ ២០២១

### ២.២.១. លទ្ធផលសម្រេចបានសំខាន់ៗ

បន្ទាប់ពីផែនការសកម្មភាពប្រចាំឆ្នាំអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ២០២១ ត្រូវបានអនុម័តនាដើមឆ្នាំ ២០២១ ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំធ្វើការផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរួមសហការ និងអនុវត្តឲ្យមានប្រសិទ្ធភាព ។

ឆ្លងតាមការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពការងារនៃការអនុវត្តរយៈពេល ១ ឆ្នាំ (២០២១) បានបង្ហាញឲ្យឃើញថា សកម្មភាពការងារ ដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២១ សម្រេចបាន ៦០ (ភាគរយ) និងមានសកម្មភាពការងារចំនួន ៤០ (ភាគរយ) មិនទាន់បានអនុវត្តន៍ពេញលេញនៅឡើយ (មូលហេតុៈ ស្ថានភាពកូវីដ-១៩ ធ្វើអោយការអនុវត្តន៍សកម្មភាពយឺតយ៉ាវ) ។

#### ២.២.១.១ ថ្នាក់ដឹកនាំ

- ការចុះសិក្សាតាមដានព័ត៌មានទូទៅលើធនធានជលផល
- ការចុះសិក្សាស្វែងយល់ពិគ្រោះយោបល់ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ Environmental think tanks និងសម្របសម្រួលទំនាក់ទំនងបណ្តាញការងារ
- ការសិក្សាស្វែងយល់ ពិគ្រោះយោបល់ ប្រមូលរាល់ធាតុចូល និងវិភាគរាល់ព័ត៌មានទិន្នន័យពាក់ព័ន្ធដើម្បីចងក្រងទស្សនៈសេចក្តីណែនាំ និងឯកសារបច្ចេកទេសសម្រាប់ថ្នាក់ដឹកនាំ អ្នកបច្ចេកទេស អ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការគាំទ្រដល់ដំណើរការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយផែនការយុទ្ធសាស្ត្រ និងផែនការចង្កុលបង្ហាញ/ ផែនការមេ សម្រាប់តំបន់ទន្លេសាប
- សិក្សាវាយតម្លៃផលចាប់នៃធនធានត្រីនៅតំបន់ស្រុកក្រគរ ខេត្តពោធិ៍សាត់

#### ២.២.១.២ ថ្នាក់អគ្គលេខាធិការដ្ឋាន

- ការចុះតាមដានទិដ្ឋភាពរួមលើបម្រែបម្រួលអាកាសធាតុ និងបាតុភូតផ្សេងៗដែលកើតមាននៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដានផលប៉ះពាល់ផ្ទាល់លើតំបន់៣

- ការចុះលើកកម្ពស់ការចូលរួមយេនឌ័រលើការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ
- ការចុះសិក្សាស្រាវជ្រាវសក្តានុពលទេសចរណ៍ និងខ្សែសង្វាក់សេវាកម្មទេសចរណ៍ធម្មជាតិ
- ការចុះសិក្សាស្រាវជ្រាវកាកសំណល់ឧបករណ៍នេសាទ
- ការចុះសិក្សាស្រាវជ្រាវកាកសំណល់ឧបករណ៍នេសាទ
- ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ អាជ្ញាធរទន្លេសាប

### ២.២.១.៣ ថ្នាក់នាយកដ្ឋាន

❖ **នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ**

- ការចុះបច្ចុប្បន្នភាពទិន្នន័យគម្រោង ថ្នាក់ក្រោមជាតិ ដែលបាន នឹងកំពុងអនុវត្តតំបន់ទន្លេសាប
- ការរៀបចំគម្រោងវិនិយោគសាធារណៈ PIP ( Public Investment Program )
- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលត្រូវបានយកចិត្តទុដាក់ប្រកបដោយប្រសិទ្ធភាព
- ប្រព័ន្ធគ្រប់គ្រងបុគ្គលិកមន្ត្រីរាជការត្រូវបានលើកកម្ពស់ដោយសមធម៌
- ការកសាងសមត្ថភាពមន្ត្រីរាជការត្រូវបានយកចិត្តទុកដាក់ក្នុងការពង្រឹងការងារ
- ចូលរួមលើកកម្ពស់ និងពង្រឹងទំនាក់ទំនងបណ្តាញការងារទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ
- រៀបចំផែនការសកម្មភាព ២០២២ របស់អាជ្ញាធរទន្លេសាប
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ផែនការសកម្មភាព ២០២១

❖ **នាយកដ្ឋានធនធានធម្មជាតិ**

- ការចុះសិក្សាស្រាវជ្រាវពីបច្ចុប្បន្នភាពធនធានជលផល (ត្រី និងក្រៅពីត្រី) និងការប្រើប្រាស់ធនធានជលផលក្នុងវារីវប្បកម្មនៅតំបន់ទីជម្រាលអាងទន្លេសាប
- ការចុះសិក្សា ស្រាវជ្រាវការប្រែប្រួលរបបជលសាស្ត្រ និងទឹកភ្លៀងព្រមទាំងផលប៉ះពាល់នៃរូបរាងស្ទឹង (River Morph-dynamic) នៃការអភិវឌ្ឍ និងការទាញយកធនធានរ៉ែនៅតំបន់ទីជម្រាលទន្លេសាប
- ការចុះសិក្សាស្រាវជ្រាវ និងតាមដានគុណភាពទឹកបឹងទន្លេសាប និងការបំពុលបរិស្ថានពីការបញ្ចេញចោលកាកសំណល់រឹង-រាវនៅតាមភូមិបណ្តែតទឹកសំខាន់ៗនៅតំបន់ទីជម្រាលអាងទន្លេសាប
- ការចុះសិក្សាតាមដានសាកល្បងស្តីពីលំហូរចូលនៃធនធានកូនត្រី និងការបំលាស់ទីចេញនៃធនធានត្រីតាមការប្រែប្រួលរបបជលសាស្ត្ររវាងទន្លេមេគង្គ និងទន្លេសាប
- ការចុះសិក្សាស្រាវជ្រាវស្តីពីបច្ចុប្បន្នភាពប្រភេទសិប្បីសត្វ វារីសត្វ ល្មូន និងផលប៉ះពាល់បរិស្ថានទឹកពីការនេសាទលៀសនៅតំបន់កោះក្អែក និងពាមបាង បឹងទន្លេឆ្មារ
- ការចុះសិក្សាស្រាវជ្រាវស្តីពីការចុះអធិការកិច្ចដែនព្រៃលិចទឹកតំបន់ ៣ និងបច្ចុប្បន្នភាពគម្របដីព្រៃលិចទឹកព្រមទាំងការប្រើប្រាស់ដីកសិកម្ម និងជីគីមី-ថ្នាំកសិកម្មនៅតំបន់ទន្លេសាប និងកោះ

❖ **នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស**

- ការចុះតាមដាន ត្រួតពិនិត្យ និងពង្រឹងការងាររបស់ ភ្នាក់ងារអាជ្ញាធរទន្លេសាប

- ការចុះសិក្សាតាមដាន និងធ្វើបច្ចុប្បន្នភាពលើផលិតផលកែច្នៃផលនេសាទនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ការចុះសិក្សាពីការធ្វើអាជីវកម្មសិប្បីសត្វ និងវាយតម្លៃផលចាប់សិប្បីសត្វនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប
- ការចុះសិក្សាស្រាវជ្រាវ និងតាមដានសង្វាក់ផលិតកម្មត្រីនុយនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប
- ការចុះសិក្សាតាមដានលើអាជីវកម្មឧរង្គសត្វ(Reptiles)នៅបណ្ដាខេត្តទាំង៦ជុំវិញបឹងទន្លេសាប
- ការចុះសិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាព បញ្ជីសារពើភ័ណ្ឌឧបករណ៍នេសាទនៅបណ្ដាខេត្តទាំង៦ជុំវិញបឹងទន្លេសាប
- ការចុះតាមដានការប្រែប្រួលគម្របដីនៅក្នុងតំបន់ទន្លេសាប (វិភាគ និងវាយតម្លៃតាមបច្ចេកវិទ្យាទូរវិញ្ញាណទៅលើភ្លើងឆេះព្រៃលិចទឹកនៅតំបន់បឹងទន្លេសាប)
- ការចុះសិក្សាស្វែងយល់ និងសិក្សាតំបន់អភិរក្សជល ផលនៅបឹងទន្លេសាប
- ការចុះសិក្សាស្រាវជ្រាវពីបម្រែបម្រួលបរិស្ថាន និងធនធានជលផលនៅតំបន់បឹងទន្លេធ្មារ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ
- ការចុះតាមដានផលនេសាទរបស់អ្នកនេសាទនៅតាមដងស្ទឹងទាំង ៤ ជុំវិញបឹងទន្លេសាប
- ការចុះសិក្សាតាមដានបរិមាណផលចាប់ឡូត៍ដាយត្រីរាជធានីភ្នំពេញ និងខេត្តកណ្ដាល

❖ **នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**

- ការសិក្សាពីបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមលើការប្រើប្រាស់ធនធានធម្មជាតិនៅភូមិបណ្ដែតទឹកបឹងទន្លេសាបក្នុងជំហាន២
- ការសិក្សាពីប្រសិទ្ធភាពការអនុវត្តច្បាប់ និងយន្តការដោះស្រាយវិវាទលើការទាញយកផលប្រយោជន៍ លើការប្រើប្រាស់ធនធានធម្មជាតិនៅតំបន់បឹងទន្លេសាបជាមួយស្ថាប័នពាក់ព័ន្ធអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានក្នុងជំហាន១
- ការចុះសិក្សាពីស្ថានភាពសង្គមកិច្ច(វិស័យអប់រំ សុខាភិបាល ការងារនិងមុខរបរ...) និងបរិស្ថានធនធានធម្មជាតិនៅខេត្តជុំវិញតំបន់បឹងទន្លេសាប
- ការរៀបចំ និងបច្ចុប្បន្នភាពប្រព័ន្ធអេឡិចត្រូនិច (Server) អាជ្ញាធរទន្លេសាប
- ការសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នជំនាញ ខេត្តជុំវិញបឹងទន្លេសាបដើម្បីប្រមូល និងចងក្រងបទដ្ឋានគតិយុត្ត/ច្បាប់នានាពាក់ព័ន្ធក្នុងកិច្ចការងារគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍បរិស្ថានធនធានធម្មជាតិ និងគោលនយោបាយ បទបញ្ញត្តិពាក់ព័ន្ធការគ្រប់គ្រងធនធានទឹក
- ការពង្រឹងបណ្ដាញទំនាក់ទំនងការងារជាមួយស្ថាប័ន និងសហគមន៍មូលដ្ឋានក្នុងការតាមដានផលប៉ះពាល់ទៅលើធនធានធម្មជាតិក្នុងជំហាន ២

- ការសិក្សាពីប្រសិទ្ធភាពការចូលរួមពីសហគមន៍នេសាទ លើការគ្រប់គ្រងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធជំហាន២
- ការសម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញផ្សព្វផ្សាយបង្កើនការយល់ដឹងពីបទបញ្ញត្តិការគ្រប់គ្រងអភិរក្សធនធានធម្មជាតិដល់សហគមន៍មូលដ្ឋាន
- ការបង្កើតវេទិកា (Platform) ចែករំលែក និងផ្សព្វផ្សាយការសិក្សាស្រាវជ្រាវពាក់ព័ន្ធសក្តានុពល និងផលប៉ះពាល់តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

## ២.៣ មេរៀន និងបទពិសោធន៍នៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២១

ឆ្លងតាមការត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២១ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានឆ្លុះបញ្ចាំងឲ្យឃើញពីបញ្ហាធំៗមួយចំនួន ដែលជាបញ្ហាប្រឈមចំពោះដំណើរការអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋាននីមួយៗ និងមិនអាចសម្រេចបានជោគជ័យទាំងស្រុងបាន ទៅតាមសកម្មភាពការងារ ដែលបានលើកឡើងក្នុងផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២ ។

បញ្ហាប្រឈម ទាំងនោះរួមមាន ៖

- ✓ សមត្ថភាពចំណេះដឹង និងបទពិសោធន៍ការងាររបស់មន្ត្រីរដ្ឋបាល និងបច្ចេកទេស នៅមានកម្រិត ទាំងការទទួលខុសត្រូវ និងការអនុវត្តការងារ
- ✓ សម្ភារៈបច្ចេកទេស ចុះអនុវត្តការងារ នៅមានការខ្វះខាត
- ✓ ការផ្តល់កិច្ចសហប្រតិបត្តិការ អាជ្ញាធរដែនដី និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ នៅមានកម្រិតដោយសារការបាត់បង់ផលប្រយោជន៍ផ្ទាល់ខ្លួនពីឈ្មួញ
- ✓ សកម្មភាពការងារ ដែលបានលើកឡើងមានលក្ខណៈបច្ចេកទេស ដែលប៉ះពាល់ដល់ទំហំថវិកា ពេលវេលា និងសមត្ថភាពមន្ត្រី មិនអាចសម្រេចបានជោគជ័យគ្រប់សកម្មភាពទាំងស្រុង ។
- ✓ ស្ថានភាពកូវីដ ១៩ ធ្វើអោយការអនុវត្តន៍សកម្មភាពយឺតយ៉ាវ

# ផ្នែកទី៣

# ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥

ការកំណត់នូវចក្ខុវិស័យ នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបគឺស្របជាមួយអាណត្តិ និងតួនាទីភារកិច្ចដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប។

ជាក់ស្តែងបច្ចុប្បន្នតំបន់បឹងទន្លេសាបត្រូវបានទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងតាមរយៈកត្តាមនុស្ស និងកត្តាប្រែប្រួលអាកាសធាតុ ដែលតម្រូវឲ្យអាជ្ញាធរទន្លេសាបចាំបាច់ពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រទំនើបដើម្បីកំណត់រាល់មូលហេតុបញ្ហាប្រឈមនិងដំណោះស្រាយផ្សេងៗនៅក្នុងតំបន់បឹងទន្លេសាប។

យោងលើអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិបណ្ឌិត **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាបសំដៅឲ្យអាជ្ញាធរទន្លេសាបពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

ហេតុដូចនេះ សម្រាប់នីតិកាលទី៦ និងជាលើកទី២ នៃការរៀបចំផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាបបានកំណត់យកចក្ខុវិស័យផ្តោតលើការសិក្សាស្រាវជ្រាវអមដោយ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងសកម្មភាពយុទ្ធសាស្ត្រដែលជាគ្រោងឆ្អឹងដ៏រឹងមាំ និងប្រទាក់ក្រឡាគ្នា រួមមានជាអាទិ៍៖

ដ្យាក្រាមទី២ គំនូសបំព្រួញរចនាសម្ព័ន្ធចក្ខុវិស័យ បេសកកម្ម និងសសរស្តម្ភ



## ៣.១- ចក្ខុវិស័យ និងបេសកកម្ម

៣.១.១. ចក្ខុវិស័យ ក្របខណ្ឌផែនការយុទ្ធសាស្ត្រ សម្រាប់អាជ្ញាធរទន្លេសាប បង្កើតឡើងដោយផ្អែកលើតួនាទី ភារកិច្ច ទស្សនវិស័យ និងបេសកកម្ម ដែលរាជរដ្ឋាភិបាលបានកំណត់ " **អាជ្ញាធរទន្លេសាបជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាបប្រកបដោយចីរភាព** " ។

៣.១.២. បេសកកម្ម ដើម្បីសម្រេចបាននូវចក្ខុវិស័យច្បាស់លាស់ខាងលើ **បេសកកម្មចំនួន៣** ត្រូវបានកំណត់ដូចខាងក្រោម៖

(១) ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព

(២) សម្របសម្រួល និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិនៃតំបន់បឹងទន្លេសាប

(៣) ពង្រឹងធនធានមនុស្ស មូលដ្ឋានទិន្នន័យ និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ។

## ៣.២- គោលដៅយុទ្ធសាស្ត្រ និងគោលបំណង

### ៣.២.១. គោលដៅយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះមាន **គោលដៅយុទ្ធសាស្ត្រចំនួន៤** គាំទ្រដល់បេសកកម្មខាងលើរួមមាន៖

១- ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

២- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា

៣- លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍

៤- ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ។

### ៣.២.២. គោលបំណង

ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងរួម គឺពង្រឹងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាបប្រកបដោយចីរភាព រវាងអាជ្ញាធរទន្លេសាបជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាប។

## ៣.៣- បាវចនា និងវចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប

### ៣.៣.១. បាវចនា

ឯកឧត្តមកិត្តិបណ្ឌិត **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប សម្រាប់នីតិកាលទី៦ នេះ បានកំណត់យកនូវបាវចនាចំនួន៣ ដូចខាងក្រោម៖

១. ជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២. ជាស្ថាប័នគ្រប់គ្រងទិន្នន័យ ព័ត៌មាន និងឯកសារស្រាវជ្រាវនៃតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៣. ការពារផលប្រយោជន៍មន្ត្រីរាជការ និងសុខដុមនីយកម្ម។

### ៣.៣.២. រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ អមដោយទីប្រឹក្សា និងជំនួយការមួយចំនួនតាមការចាំបាច់ និងមានអគ្គលេខាធិការដ្ឋានជាសេនាធិការផ្ទាល់ដើម្បីចាត់ចែងការងារទូទៅប្រចាំថ្ងៃ និងមាននាយកដ្ឋានក្រោមឱវាទចំនួន៤ រួមមាន៖

១. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

២. នាយកដ្ឋានធនធានធម្មជាតិ

៣. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

៤. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ។

ដ្យាក្រាមទី៣ រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប



## ៣.៤- ទិសដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រដែលជាលទ្ធផលរំពឹងទុកទាំង៤ខាងលើ អាជ្ញាធរទន្លេសាប បានកំណត់នូវទិសដៅយុទ្ធសាស្ត្រចំនួន១០ ដែលមានជាអាទិ៍ ៖

១.១. ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីសស្តែមតំបន់បឹងទន្លេសាប

១.២. ពង្រឹងប្រសិទ្ធភាព នៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត

១.៣.ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើអេកូស៊ីសស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិទាំងលើវិស័យសង្គម/សេដ្ឋកិច្ច

២.១. ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប

២.២. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា

៣.១. ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់

៣.២.លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

៤.១. លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព

៤.២. អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់បឹងទន្លេសាប

៤.៣. ពង្រឹងសមត្ថភាពមន្ត្រីរាជការលើការសិក្សាស្រាវជ្រាវ តាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប ។

## ៣.៥- សកម្មភាពយុទ្ធសាស្ត្រ (សកម្មភាពគន្លឹះ)

ដើម្បីជាគ្រឹះក្នុងការសម្រេចតាមចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រនេះ សកម្មភាពយុទ្ធសាស្ត្រដែលជាកត្តាគន្លឹះ និងមានភាពប្រទាក់ក្រឡាគ្នាចំនួន២៧ សកម្មភាពគន្លឹះត្រូវបានកំណត់ដែលមានជាអាទិ៍៖

១.១.១. ពិនិត្យឡើងវិញនូវសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ

១.១.២. ធ្វើការកំណត់ដែនវិសាលភាពដែលត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ

១.១.៣. សិក្សាស្រាវជ្រាវ និងវាយតម្លៃលើបច្ចុប្បន្នភាពធនធានធម្មជាតិតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

១.២.១. តាមដានត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ដែលមានស្រាប់ និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប

១.២.២. កំណត់តម្រូវការជាមូលដ្ឋាន និងតាមដានពិនិត្យជាប្រចាំរាល់បញ្ហាដែលជួបប្រទះនៅតាមទីតាំងក្នុងតំបន់២ តំបន់៣ ជុំវិញបឹងទន្លេសាប

១.៣.១. សិក្សាតាមដានលើរបបជលសាស្ត្រ គុណភាពទឹក ព្រៃលិចទឹក ជីវចម្រុះ (ធនធាន

ផលផល ប្រភេទ Flora and Fauna តាមទីតាំង និងរដូវកាល) សេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជនដែលមានភាពទំនាក់ទំនងនឹងសម្ពាធ នៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ

១.៣.២. ពង្រឹងការសិក្សាតាមដានប្រភេទព្រៃលិចទឹកតំបន់៣ និងអធិការកិច្ចដែនអភិរក្ស ព្រៃលិចទឹកតំបន់៣

២.១.១. ជំរុញប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានវិទ្យាអាជ្ញាធរទន្លេសាប

២.១.២. រៀបចំកសាងផលិតរបាយការណ៍ ស្តីពីស្ថានភាពបឹងទន្លេសាប

២.១.៣. ផលិតរូបភាពផែនទី/រូបថតលើអាកាស និងធ្វើបច្ចុប្បន្នភាពនៃតំបន់បឹងទន្លេសាប

២.២.១. ជំរុញកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ ព្រមទាំងផលិត ឯកសារស្រាវជ្រាវ

២.២.២. កសាង និងពង្រឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍លើការសិក្សាស្រាវជ្រាវ និងផ្នែកបច្ចេកទេស

២.២.៣. រៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងបណ្តាញទំនាក់ទំនងការងារក្នុងភាពជាដៃគូក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានធម្មជាតិតំបន់បឹងទន្លេសាប

៣.១.១. ស្វែងយល់ និងកំណត់ហេតុលើបញ្ហាវិវាទក្នុងតំបន់បឹងទន្លេសាប

៣.១.២. លើកកម្ពស់យន្តការសម្របសម្រួល និងកិច្ចទំនាក់ទំនង

៣.១.៣. ពង្រឹងការប្រឹក្សាយោបល់អន្តរវិស័យ និងដំណោះស្រាយ

៣.២.១. ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយអន្តរក្រសួង/ស្ថាប័ន និងដៃគូអភិវឌ្ឍន៍

៣.២.២. ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលរវាងសហគមន៍មូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

៣.២.៣. ជំរុញលើការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន លើមុខរបរសមស្របក្រៅពីធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព

៤.១.១. កសាងសមត្ថភាព និងពង្រឹងអង្គភាព/ស្ថាប័ន

៤.១.២. ការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប

៤.២.១. រៀបចំកសាងផែនការយុទ្ធសាស្ត្រសម្រាប់តំបន់បឹងទន្លេសាប

៤.២.២. រៀបចំគោលនយោបាយការគ្រប់គ្រង និងអភិវឌ្ឍតំបន់បឹងទន្លេសាប

៤.២.៣. រៀបចំកសាងផែនការចង្អុលបង្ហាញ/ផែនការមេសម្រាប់តំបន់បឹងទន្លេសាប

៤.៣.១. លើកកម្ពស់ការយល់ដឹងលើប្រធានបទនៃការសិក្សាស្រាវជ្រាវដែលជាតម្រូវការជាក់ស្តែងរបស់អាជ្ញាធរទន្លេសាប

៤.៣.២. លើកកម្ពស់យេនឌ័រក្នុងវិស័យធនធានធម្មជាតិ

៤.៣.៣. ធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប ក្នុងការអនុវត្តតួនាទីភារកិច្ចប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងភាពថ្លៃប្រឌិតខ្ពស់

## តារាងម៉ាទ្រិចទី១ សកម្មភាពយុទ្ធសាស្ត្រ( សកម្មភាពគន្លឹះ )

| គោលដៅ/ទិសដៅ | | សកម្មភាពគន្លឹះ/ធាតុចេញ | អាទិភាព (ខ្ពស់ មធ្យម ទាប) |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ១. ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប | | | |
| ១.១ | ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីស្ទែមតំបន់បឹងទន្លេសាប | ១.១.១.ពិនិត្យឡើងវិញនូវសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ | ខ្ពស់ |
| | | ១.១.២.ធ្វើការកំណត់ដែនវិសាលភាពដែលត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ | មធ្យម |
| | | ១.១.៣.សិក្សាស្រាវជ្រាវ និងវាយតម្លៃលើបច្ចុប្បន្នភាពធនធានធម្មជាតិតំបន់បឹងទន្លេសាបនិងតំបន់ពាក់ព័ន្ធ | ខ្ពស់ |
| ១.២ | ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត | ១.២.១.តាមដានត្រួតពិនិត្យគម្រោងដែលមានស្រាប់ និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប | មធ្យម |
| | | ១.២.២.កំណត់តម្រូវការជាមូលដ្ឋាន និងតាមដានពិនិត្យជាប្រចាំរាល់បញ្ហាដែលជួបប្រទះនៅតាមទីតាំងក្នុងតំបន់២ និងតំបន់៣ជុំវិញតំបន់បឹងទន្លេសាប | មធ្យម |
| ១.៣ | ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើអេកូស៊ីស្ទែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុ តំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច | ១.៣.១.សិក្សាតាមដានលើរបបជលសាស្ត្រ គុណភាពទឹក ព្រៃលិចទឹក ជីវចម្រុះ( ធនធាន ជលផល ប្រភេទ Flora and Fauna តាមទីតាំង និងរដូវកាល ) សេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជនដែលមានភាពទំនាក់ទំនងនឹងសម្ពាធនៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ | ខ្ពស់ |
| | | ១.៣.២.ពង្រឹងការសិក្សាតាមដានប្រភេទព្រៃលិចទឹកតំបន់៣ និងអធិការកិច្ចដែនអភិរក្សព្រៃលិចទឹកតំបន់៣ | ខ្ពស់ |

| | | | |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រទី២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា | | | |
| ២.១ | ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប | ២.១.១.ជំរុញប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងព័ត៌មានវិទ្យាអាជ្ញាធរទន្លេសាប | ខ្ពស់ |
| | | ២.១.២.រៀបចំកសាងផលិតរបាយការណ៍ស្តីពីស្ថានភាពតំបន់បឹងទន្លេសាប | ខ្ពស់ |
| | | ២.១.៣.ផលិតរូបភាពផែនទី/រូបថតលើអាកាស និងធ្វើបច្ចុប្បន្នភាពនៃតំបន់បឹងទន្លេសាប | ខ្ពស់ |
| ២.២ | ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា | ២.២.១.ជំរុញកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ ព្រមទាំងផលិតឯកសារស្រាវជ្រាវ | មធ្យម |
| | | ២.២.២.កសាង និងពង្រឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍លើការសិក្សាស្រាវជ្រាវ និងផ្នែកបច្ចេកទេស | ខ្ពស់ |
| | | ២.២.៣.រៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងបណ្តាញទំនាក់ទំនងការងារក្នុងភាពជាដៃគូលើការគ្រប់គ្រង និងអភិវឌ្ឍធនធានធម្មជាតិ តំបន់បឹងទន្លេសាប | មធ្យម |
| | | | |
| គោលដៅយុទ្ធសាស្ត្រទី៣. លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ | | | |
| ៣.១ | ជំរុញប្រសិទ្ធភាព យន្តការសម្របសម្រួល និងប្រឹក្សាយោបល់ | ៣.១.១.ស្វែងយល់ និងកំណត់ហេតុលើបញ្ហាវិវាទក្នុងតំបន់បឹងទន្លេសាប | មធ្យម |
| | | ៣.១.២.លើកកម្ពស់យន្តការសម្របសម្រួល និងកិច្ចទំនាក់ទំនង | មធ្យម |
| | | ៣.១.៣.ពង្រឹងការប្រឹក្សាយោបល់អន្តរវិស័យ និងដំណោះស្រាយ | ខ្ពស់ |
| ៣.២ | លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ | ៣.២.១.ជម្រុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយអន្តរក្រសួង/ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ | មធ្យម |
| | | ៣.២.២.ជំរុញកិច្ចសហប្រតិបត្តិការ និង | មធ្យម |

| | | | |
|---|---|---|---|
| | | សម្របសម្រួលជាមួយសហគមន៍មូលដ្ឋានក្នុងតំបន់បឹងទន្លេសាប | |
| | | ៣.២.៣.ជំរុញការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានលើមុខរបរសមស្របក្រៅពីធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបប្រកប ដោយចីរភាព | មធ្យម |
| គោលដៅយុទ្ធសាស្ត្រទី៤. ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ | | | |
| ៤.១ | លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព | ៤.១.១.កសាងសមត្ថភាព និងការពង្រឹងអង្គភាពស្ថាប័ន | ខ្ពស់ |
| | | ៤.១.២.ការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប | ខ្ពស់ |
| ៤.២ | អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់ទន្លេសាប | ៤.២.១.រៀបចំកសាងផែនការយុទ្ធសាស្ត្រសម្រាប់តំបន់បឹងទន្លេសាប | ខ្ពស់ |
| | | ៤.២.២.រៀបចំគោលនយោបាយគ្រប់គ្រងអាង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប | ខ្ពស់ |
| | | ៤.២.៣.រៀបចំកសាងផែនការចង្អុលបង្ហាញ/ផែនការមេសម្រាប់តំបន់បឹងទន្លេសាប | ខ្ពស់ |
| ៤.៣ | ពង្រឹងសមត្ថភាពមន្ត្រីលើការសិក្សាស្រាវជ្រាវតាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប | ៤.៣.១.លើកកម្ពស់ការយល់ដឹងលើប្រធានបទនៃការសិក្សាស្រាវជ្រាវដែលជាតម្រូវការជាក់ស្តែងរបស់អាជ្ញាធរទន្លេសាប | មធ្យម |
| | | ៤.៣.២.លើកកម្ពស់យេនឌ័រក្នុងវិស័យធនធានធម្មជាតិ | ខ្ពស់ |
| | | ៤.៣.៣.ធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាបក្នុងការអនុវត្តតួនាទី ភារកិច្ចប្រកបដោយតម្លាភាពប្រសិទ្ធភាព និងភាពច្នៃប្រឌិតខ្ពស់ | ខ្ពស់ |

# ផ្នែកទី ៤

# ផែនការសកម្មភាពការងារឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប

## ៤.១. សេចក្តីផ្តើម

ផែនការសកម្មភាពការងារឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប គឺជាសកម្មភាពការងារលម្អិត សម្រាប់ប្រតិបត្តិការងារជាក់ស្តែង ដោយមានការចូលរួមសហការពីបណ្តាក្រសួងស្ថាប័នទាំងក្នុងកម្រិត ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ សង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បី ជម្រុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ឲ្យទទួលបានជោគជ័យ ។

ជារួម ផែនការសកម្មភាពការងារ ត្រូវបានរៀបចំឡើងដោយបន្សុីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ នៃផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ របស់អាជ្ញាធរទន្លេសាប (២០២១-២០២៥) ។ ជាពិសេសស្របទៅតាមតួនាទីភារកិច្ចការងារទទួលខុសត្រូវ ដូចបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងារស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

## ៤.២ សកម្មភាពការងារឆ្នាំ ២០២២ របស់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាបបានរៀបចំ ផែនការសកម្មភាពការងារឆ្នាំ ២០២២ ក្នុងនោះមានសកម្មភាពចំនួន ៥៧ សកម្មភាព ដែលស្ថិតនៅក្នុងសកម្មភាពគន្លឹះ ទិសដៅយុទ្ធសាស្ត្រ និងគោលដៅយុទ្ធសាស្ត្រ/សសរស្តម្ភ ដូចខាងក្រោម៖

គោលដៅយុទ្ធសាស្ត្រ ១. ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

ទិសដៅយុទ្ធសាស្ត្រ ១.១. ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីសស្តែមតំបន់បឹងទន្លេសាប

សកម្មភាពគន្លឹះ ១.១.១. ពិនិត្យឡើងវិញនូវសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍

សកម្មភាពគន្លឹះ ១.១.២. ធ្វើការកំណត់ដែនវិសាលភាពដែលត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ

សកម្មភាពគន្លឹះ ១.១.៣. សិក្សាស្រាវជ្រាវ និងវាយតម្លៃលើបច្ចុប្បន្នភាពធនធានធម្មជាតិតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

សកម្មភាព ១.១.៣.១. សិក្សាវាយតម្លៃផលចាប់ នៃធនធានត្រីនៅ ខេត្តកំពង់ឆ្នាំង

សកម្មភាព ១.១.៣.២. តាមដានផលនេសាទរបស់អ្នកនេសាទនៅតាមដងស្ទឹងទាំង ០៤ ជុំវិញបឹងទន្លេសាប

សកម្មភាព ១.១.៣.៣. សិក្សាវាយតម្លៃផលចាប់ត្រី និងការធ្វើអាជីវកម្មតាមដងទន្លេសាបរាជធានីភ្នំពេញ និងខេត្តកណ្តាល (ឧបករណ៍ឡូត៍ដាយ និងក្រៅពីឡូត៍ដាយ)

ទិសដៅយុទ្ធសាស្ត្រ ១.២. ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត

សកម្មភាពគន្លឹះ ១.២.១. តាមដានត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ដែលមានស្រាប់ និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប

សកម្មភាព ១.២.១.១. បច្ចុប្បន្នភាពទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ ដែលបាននឹងកំពុងអនុវត្តន៍តំបន់ទន្លេសាប

សកម្មភាព ១.២.១.២. រៀបចំគម្រោងវិនិយោគសាធារណៈ PIP ( Public Investment Program )

សកម្មភាពគន្លឹះ ១.២.២. កំណត់តម្រូវការជាមូលដ្ឋាន និងតាមដានពិនិត្យជាប្រចាំរាល់បញ្ហាដែលជួបប្រទះនៅតាមទីតាំងក្នុងតំបន់២ តំបន់៣ ជុំវិញបឹងទន្លេសាប

**ទិសដៅយុទ្ធសាស្រ្ត ១.៣.** ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់នៃអេកូស៊ីស្ទែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច

សកម្មភាពគន្លឹះ ១.៣.១. សិក្សាតាមដានលើរបបជលសាស្រ្ត គុណភាពទឹក ព្រៃលិចទឹក ជីវចម្រុះ (ធនធានជលផល ប្រភេទFlora and Fauna តាមទីតាំង និងរដូវកាល) សេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជនដែលមានភាពទំនាក់ទំនងនឹងសម្ពាធនៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍន៍

សកម្មភាព ១.៣.១.១. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃបទល្មើសនេសាទក្នុងតំបន់បឹងទន្លេសាបទាំង ០៦ ខេត្តជុំវិញបឹងទន្លេសាប

សកម្មភាព ១.៣.១.២. សិក្សាស្រាវជ្រាវសក្តានុពលទេសចរណ៍ និងខ្សែសង្វាក់សេវាកម្មទេសចរណ៍ធម្មជាតិ នៅខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង

សកម្មភាព ១.៣.១.៣. សិក្សាស្រាវជ្រាវកាកសំណល់ឧបករណ៍នេសាទ នៅខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ បញ្ជ្រាប និងលើកកម្ពស់ការយល់ដឹងស្តីពីការគ្រប់គ្រងកាកសំណល់រឹងនៅភូមិបណ្តែតទឹកជុំវិញបឹងទន្លេសាប

សកម្មភាព ១.៣.១.៤. សិក្សាស្វែងយល់ពីការប្រើប្រាស់ ប្រភេទថាមពល របស់ប្រជាជនរស់នៅភូមិសាស្រ្តបណ្តែតទឹកនៃខេត្តទាំង ៦ជុំវិញបឹងទន្លេសាប

សកម្មភាព ១.៣.១.៥. សិក្សាតាមដាន និងធ្វើបច្ចុប្បន្នភាពលើផលិតផលកែច្នៃផលនេសាទនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

សកម្មភាព ១.៣.១.៦. សិក្សាស្រាវជ្រាវ និងតាមដានការធ្វើអាជីវកម្មសិប្បីសត្វនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប

សកម្មភាព ១.៣.១.៧. សិក្សាស្រាវជ្រាវ និងតាមដានសង្វាក់ផលិតកម្មត្រីនុយនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប

សកម្មភាព ១.៣.១.៨. សិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌឧបករណ៍នេសាទនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

សកម្មភាព ១.៣.១.៩. សិក្សាតាមដានលើអាជីវកម្មលើឧរង្គសត្វ (Reptiles) នៅបណ្តាខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប

សកម្មភាព ១.៣.១.១០. សិក្សាស្រាវជ្រាវ និងតាមដានការធ្វើអាជីវកម្មកំពិសនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

សកម្មភាព ១.៣.១.១១. សិក្សាស្រាវជ្រាវ និងតាមដានការធ្វើអាជីវកម្មដោយឧបករណ៍បរនៅខេត្តទាំង ០៦ ជុំវិញបឹងទន្លេសាប

សកម្មភាព ១.៣.១.១២. សិក្សាស្រាវជ្រាវពីបម្រែបម្រួលបរិស្ថាន និងធនធានជលផលនៅឋបនីយ៍ជីវៈមណ្ឌលបឹងទន្លេឆ្មា ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ

សកម្មភាព ១.៣.១.១៣. សិក្សាស្វែងយល់ និងសិក្សាតំបន់អភិរក្សជលផលនៅបឹងទន្លេសាប

សកម្មភាព ១.៣.១.១៤. តាមដានការប្រែប្រួលគម្របដីនៅក្នុងតំបន់ទន្លេសាប (វិភាគ និងវាយតម្លៃតាមបច្ចេកវិទ្យាទូរវិញ្ញាណទៅលើភ្លើងឆេះព្រៃលិចទឹកនៅតំបន់ទន្លេសាប)

សកម្មភាព ១.៣.១.១៥. សិក្សាស្រាវជ្រាវស្តីពីបច្ចុប្បន្នភាពធនធានជលផល (ត្រី ក្រៅពីត្រី និងវារីសត្វ) និងការប្រើប្រាស់ធនធានជលផលក្នុងវិស័យវារីវប្បកម្ម (ត្រី និងក្រពើ) នៅតំបន់ទីជម្រាលអាងទន្លេសាប

សកម្មភាព ១.៣.១.១៦. សិក្សាតាមដានរបបជលសាស្ត្រ គុណភាពទឹកបឹងទន្លេសាប និងការបំពុលបរិស្ថានពីការបញ្ចេញចោលកាកសំណល់រឹង-រាវនៅតាមភូមិបណ្តែតទឹកសំខាន់ៗព្រមទាំងលំហូរធនធានខ្សាច់ និងវាយតម្លៃប៉ះពាល់កំណកខ្សាច់បាតស្ទឹង នៅតំបន់ទីជម្រាលអាងទន្លេសាប

សកម្មភាព ១.៣.១.១៧. សិក្សាតាមដានស្តីពី លំហូរចូលនៃធនធានកូនត្រី និងការបំលាស់ទីចេញនៃធនធានត្រីតាមការប្រែប្រួលរបបជលសាស្ត្ររវាងទន្លេមេគង្គ-ទន្លេសាប (កំពង់ចាម កណ្តាល និងកំពង់ឆ្នាំង) ជំហានទី ២

សកម្មភាព ១.៣.១.១៨. គម្រោងសិក្សាស្រាវជ្រាវស្តីពី បច្ចុប្បន្នភាពប្រភេទសិប្បីសត្វ វារីសត្វ ល្មូន និងផលប៉ះពាល់ បរិស្ថានទឹកពីការនេសាទលៀសនៅតំបន់កោះក្អែក និងពាមបាង-ទន្លេឆ្មា (ជំហានទី ២)

សកម្មភាព ១.៣.១.១៩. សិក្សាពីសេដ្ឋកិច្ចសង្គម ៖ បញ្ហាប្រឈម ចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅភូមិបណ្តែតទឹកបឹងទន្លេសាប

សកម្មភាព ១.៣.១.២០. សិក្សាពីបញ្ហាប្រឈមចំពោះវិស័យសង្គមកិច្ច ការងារនិងមុខរបរ... របស់ប្រជាពលរដ្ឋរស់នៅតំបន់ទន្លេសាប

### សកម្មភាពគន្លឹះ ១.៣.២. ពង្រឹងការសិក្សាតាមដានប្រភេទព្រៃលិចទឹកតំបន់៣និងអធិការកិច្ចដែនអភិរក្សព្រៃលិចទឹកតំបន់ ៣

សកម្មភាព ១.៣.២.១. សិក្សាស្រាវជ្រាវ ស្តីពីការចុះអធិការកិច្ចដែនព្រៃលិចទឹកតំបន់ ៣ និងការប្រែប្រួលព្រៃលិចទឹកតំបន់ ៣ និងការប្រើប្រាស់ដីកសិកម្ម និងជីគីមីថ្នាំកសិកម្មនៅក្នុងទី-ជម្រាលអាងទន្លេសាប

គោលដៅយុទ្ធសាស្ត្រ ២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា
ទិសដៅយុទ្ធសាស្ត្រ ២.១. ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប

សកម្មភាពគន្លឹះ ២.១.១. ជំរុញប្រសិទ្ធភាពគ្រប់គ្រងទិន្នន័យ និងព័ត៌មានវិទ្យាអាជ្ញាធរទន្លេសាប
សកម្មភាព ២.១.១.១. រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ អាជ្ញាធរទន្លេសាប
សកម្មភាព ២.១.១.២. រៀបចំ និងបច្ចុប្បន្នភាពប្រព័ន្ធអេឡិចត្រូនិច (Server) អាជ្ញាធរទន្លេសាប
សកម្មភាពគន្លឹះ ២.១.២. រៀបចំកសាងផលិតរបាយការណ៍ស្តីពីស្ថានភាពបឹងទន្លេសាប
សកម្មភាពគន្លឹះ ២.១.៣. ផលិតរូបភាពផែនទី/រូបភាពលើអាកាស និងបច្ចុប្បន្នភាពនៃតំបន់ទន្លេសាប
សកម្មភាព ២.១.៣.១. ចុះផលិត និងចងក្រងវីដេអូឯកសារអំពីសកម្មភាពសិក្សាស្រាវជ្រាវ នៅក្នុងផែនការសកម្មភាពការងារឆ្នាំ ២០២២

ទិសដៅយុទ្ធសាស្ត្រ ២.២. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា

សកម្មភាពគន្លឹះ ២.២.១. ជំរុញកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរ ចំណេះដឹង បទពិសោធន៍ ព្រមទាំងផលិតឯកសារសិក្សាស្រាវជ្រាវ
សកម្មភាព ២.២.១.១. រៀបចំកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោធន៍ ផ្សារភ្ជាប់នឹងវិស័យធនធានធម្មជាតិ
សកម្មភាពគន្លឹះ ២.២.២. កសាងពង្រីកទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍលើការសិក្សាស្រាវជ្រាវ និងផ្នែកបច្ចេកទេស
សកម្មភាព ២.២.២.១. សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន ជំនាញ ខេត្តជុំវិញបឹងទន្លេសាប ដើម្បីប្រមូល និងចងក្រងបទដ្ឋានគតិយុត្ត/ច្បាប់នានាពាក់ព័ន្ធក្នុងកិច្ចការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍បរិស្ថានធនធានធម្មជាតិ និងគោលនយោបាយ បទបញ្ញត្តិពាក់ព័ន្ធការគ្រប់គ្រងធនធានទឹក
សកម្មភាពគន្លឹះ ២.២.៣. រៀបចំប្រព័ន្ធព័ត៌មានវិទ្យា និងបណ្តាញទំនាក់ទំនងការងារក្នុងភាពជាដៃគូក្នុង ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិតំបន់បឹងទន្លេសាប
សកម្មភាព ២.២.៣.១. ពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងប្រមូលចងក្រងទិន្នន័យ ព័ត៌មាន អំពីផលប៉ះពាល់លើបរិស្ថានធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប

គោលដៅយុទ្ធសាស្ត្រ ៣. លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
ទិសដៅយុទ្ធសាស្ត្រ ៣.១. ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់
សកម្មភាពគន្លឹះ ៣.១.១. ស្វែងយល់ និងកំណត់ហេតុលើបញ្ហាវិវាទក្នុងតំបន់ទន្លេសាប
សកម្មភាព ៣.១.១.១. សិក្សាពីប្រសិទ្ធភាពការអនុវត្តច្បាប់ និងស្វែងយល់ដោះស្រាយវិវាទលើការទាញយកផលប្រយោជន៍លើការប្រើប្រាស់ធនធានធម្មជាតិនៅតំបន់ទន្លេសាប

សកម្មភាពគន្លឹះ ៣.១.២. លើកកម្ពស់យន្តការសម្របសម្រួល និងកិច្ចទំនាក់ទំនង

| | |
|---|---|
| សកម្មភាព ៣.១.២.១. | បង្កើតវេទិកាបណ្តាញផ្សព្វផ្សាយ ចែករំលែក និងផ្សព្វផ្សាយការសិក្សាស្រាវជ្រាវពាក់ព័ន្ធសក្តានុពល និងផលប៉ះពាល់តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ |
| សកម្មភាព ៣.១.២.២. | ពិគ្រោះយោបល់ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ Environmental Think Tanks និងសម្របសម្រួលទំនាក់ទំនងបណ្តាញការងារ think tanks |

សកម្មភាពគន្លឹះ ៣.១.៣ ពង្រឹងការប្រឹក្សាយោបល់អន្តរវិស័យ និងដំណោះស្រាយ

| | |
|---|---|
| សកម្មភាព ៣.១.៣.១. | សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញផ្សព្វផ្សាយបង្កើនការយល់ដឹងពីបទបញ្ញត្តិការគ្រប់គ្រង អភិរក្សធនធានធម្មជាតិ ដល់សហគមន៍មូលដ្ឋាន |

**ទិសដៅយុទ្ធសាស្ត្រ ៣.២.** លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ

សកម្មភាពគន្លឹះ ៣.២.១. ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយអន្តរក្រសួង/ស្ថាប័ន និងដៃគូអភិវឌ្ឍ

| | |
|---|---|
| សកម្មភាព ៣.២.១.១. | ពង្រឹងទំនាក់ទំនងបណ្តាញការងារទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ |

សកម្មភាពគន្លឹះ ៣.២.២. ជំរុញកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលរវាងសហគមន៍មូលដ្ឋានក្នុងតំបន់ទន្លេសាប

| | |
|---|---|
| សកម្មភាព ៣.២.២.១. | សិក្សាពីប្រសិទ្ធិភាពលើការអនុវត្តនិងយន្តការគន្លឹះក្នុងការកសាងផែនការគ្រប់គ្រងសហគមន៍ ប្រកបដោយនិរន្តរភាពនៅតំបន់បឹងទន្លេសាប ជំហាន១ ឆ្នាំ២០២២ |

សកម្មភាពគន្លឹះ ៣.២.៣. ជំរុញការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានលើមុខរបរសមស្របក្រៅពីធនធានធម្មជាតិក្នុងតំបន់ទន្លេសាបប្រកបដោយចីរភាព

**គោលដៅយុទ្ធសាស្ត្រ ៤.** ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ

**ទិសដៅយុទ្ធសាស្ត្រ ៤.១.** លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើការស្ថាប័នប្រកបដោយចីរភាព

សកម្មភាពគន្លឹះ ៤.១.១. កសាងសមត្ថភាព និងពង្រឹងអង្គភាព/ស្ថាប័ន

| | |
|---|---|
